# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១៩៩២ អ.ក
ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១

**សាលក្រមព្រហ្មទណ្ឌ**
លេខ ៤៣ "ផ.ក្រ"
ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ៨៖៣០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល ជាប្រធានក្រុមប្រឹក្សា

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្តាល ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខត្តកណ្តាល ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៩២ អ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០២១ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] ជីតា ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិដើមស្ពែង សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម៉ៅ "រស់" ម្តាយឈ្មោះ [redacted] សុខឡាំង "ស្លាប់" ប្រពន្ធឈ្មោះ វី គ្មានកូន ជាអនីតិជន ទោសពីមុន គ្មាន (ក្នុងឃុំ) ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤៨២១ ដកបឃខ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ៖ លួច (ម៉ូតូ) ប្រព្រឹត្តនៅស្តៅកន្លែង៤ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២២ និង៣០ នាទីយប់ មានករណី លួច (ម៉ូតូ) កើតឡើងនៅចំណុចភូមិស្តៅកន្លែង០៤ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលបង្កឡើងដោយជន...



Scanned with CamScanner

ជាប់ចោទឈ្មោះ [redacted] ជីតា បានជិះរ៉ឺម៉កកង់បីមកពីភ្នំពេញទៅផ្ទះនៅភូមិព្រែកប៉ុល ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្ត កណ្ដាល ជាមួយប្អូនប្រុសឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ ០៩ឆ្នាំ។ លុះពេលធ្វើដំណើរមកដល់ចំណុចកើតហេតុ ដោយបានឃើញម៉ូតូម៉ាកគុបជ្រុង C90 ពណ៌ខៀវ ពាក់ស្លាកលេខ ធ.១០៦៨ របស់ជនរងគ្រោះឈ្មោះ [redacted] ចន្ធូ ភេទស្រី អាយុ ៣៨ឆ្នាំ ដែលកំពុងចតទុកនៅក្នុងផ្ទះ ។ ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] ជីតា បានឱ្យកង់បីឈប់ ហើយបានដើរចូលទៅក្នុងផ្ទះជនរងគ្រោះ និងធ្វើសកម្មភាពលួចយកម៉ូតូរបស់ជនរងគ្រោះ ខណៈពេលជនជាប់ចោទកំពុងបណ្ដើរម៉ូតូចេញ ក៏ស្រាប់តែជនរងគ្រោះបានឮសម្លេងម៉ូតូ និងបានចេញមកឃើញជនជាប់ចោទកំពុងតែបណ្ដើរម៉ូតូ ក៏បានចាប់ខ្លួនជនជាប់ចោទ បញ្ជូនឱ្យសមត្ថកិច្ចតែម្តង កន្លងមកជនជាប់ចោទឈ្មោះ [redacted] ជីតា ធ្លាប់ធ្វើសកម្មភាពលួចទ្រព្យសម្បត្តិប្រជាពលរដ្ឋក្នុងភូមិជាច្រើននាក់ និងក៏ជាមនុស្សញៀនថ្នាំញៀនផងដែរ ។

**-បានឃើញ** របាយការណ៍លេខ ០០៩ រ.ប.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៨៤០ ដកសស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **១២៥ ដកសព** ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ **១៤៩ ដកដស** ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្ដាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ជីតា បានឆ្លើយថា៖ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១០៖៣០ នាទីយប់ ខ្លួននិងឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ ០៩ឆ្នាំ បានជិះម៉ូតូកង់បីជាមួយបងប្រុសម្នាក់ឈ្មោះ បារាំង អាយុប្រហែល ៣០ឆ្នាំ រស់នៅម្តុំច្បារអំពៅ ពីភ្នំពេញទៅផ្ទះនៅភូមិព្រែកប៉ុល ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល លុះពេលធ្វើដំណើរតាមផ្លូវមកដល់ចំណុចភូមិស្តៅកន្លែង៤ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក៏បានប្រទះឃើញម៉ូតូម៉ាកគប់ជ្រុង ដែលគេចតចោលនៅមុខផ្ទះ មិនមានចាក់សោរក រួចឈ្មោះ បារាំង ក៏បានខ្លួនចូលទៅលួចយកម៉ូតូនោះ ។ ខ្លួនក៏បានចូលទៅអូសម៉ូតូនោះ ក៏ស្រាប់តែម្ចាស់គេឃើញទាន់ ហើយចាប់ខ្លួនប្រគល់ឱ្យសមត្ថកិច្ចតែម្តង ។ ខ្លួនធ្លាប់លួចគេបានចំនួន ០៥ដងហើយ គឺលួចមាន់ ទូរស័ព្ទ លុយ ម៉ូតូ និងប៉ុស្តិ៍ផ្សារដែក ហើយខ្លួនក៏ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៦ខែ ពីបទលួចដែរ ទើបតែចេញនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ។ ចំពោះឈ្មោះ បារាំង គឺខ្លួនធ្លាប់លួចជាមួយគាត់បានចំនួន ២-៣ដងដែរ ។ សំណូមពរ សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ចាន់ បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនបានយកម៉ូតូមួយគ្រឿងម៉ាកគុបជ្រុងពណ៌ខៀវ ពាក់ស្លាកលេខ ធ១០៦៨ ភព ចតទុកចោលមុខផ្ទះរួចក៏សម្រាក

លុះដល់ម៉ោង២២ ក៏លឺសម្លេងគ្រោកៗ និងសំលេងឆ្កែព្រុស ខ្លួនក្រោកពីដេកចុះមកមើល ក៏មិនឃើញម៉ូតូ រួចខ្លួនក៏ស្រែកអោយគេជួយរក រួចក៏ឃើញក្មេងប្រុសម្នាក់អាយុប្រហែល១៦ឆ្នាំ កំពុងបណ្តើរម៉ូតូខ្លួនតាមផ្លូវ ខ្លួនបានឃាត់នៅកន្លែង ហើយបានប្តឹងសមត្ថកិច្ចប៉ុស្តិ៍នគរបាលដីឥដ្ឋ ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ជនជាប់ចោទគឺជាចោរអាជីព លួចពីតូចទៅធំ ជនជាប់ចោទទើបមានអាយុ ១៦ឆ្នាំ តែធ្លាប់បានលួចច្រើនដង ហើយធ្លាប់ជាប់ពន្ធនាគារទៀត ។ នៅដំណាក់កាលស៊ើបសួរ ជនជាប់ចោទបានព្យាយាមលាក់បាំងពីបក្សពួក ហើយទើបមកសារភាពនាពេលសវនាការនេះ គឺអាចវាយតម្លៃបានថា ជនជាប់ចោទមិនមានការរាងចាល គ្មានការភ្ញាក់រឭកទេ ។ ហេតុនេះស្នើសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទក្នុងកម្រិតអតិបរមា មិនគប្បីផ្តល់ស្ថានសម្រាលទេ ។

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានសន្និដ្ឋានថា៖ កូនក្តីខ្លួនជាអនីតិជន ដែលងាយនឹងប្រព្រឹត្តបទល្មើសតាមការអូសទាញ ហើយមូលហេតុដែលកូនក្តីខ្លួនលាក់បាំងបក្សពួក គឺដោយសារកូនក្តីខ្លួនមិនយល់ ងាយនឹងអូសទាញ ហេតុនេះស្នើសុំស្ថានសម្រាលទោលសដល់កូនក្តីខ្លួន ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២២ និង៣០ នាទីយប់ ជនជាប់ចោទឈ្មោះ [redacted] ជីតា និងឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ ០៩ឆ្នាំ បានជិះរ៉ឺម៉កកង់បីជាមួយឈ្មោះ **បារាំង** ពីភ្នំពេញទៅផ្ទះនៅភូមិព្រែកប៉ុល ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល លុះពេលធ្វើដំណើរមកដល់ចំណុចកើតហេតុ ដោយបានឃើញម៉ូតូម៉ាកឌុបជ្រុង C90 ពណ៌ខៀវ ពាក់ស្លាកលេខ ធ.១០៦៨ របស់ជនរងគ្រោះឈ្មោះ [redacted] ចន្ធូ ភេទស្រី អាយុ ៣៨ឆ្នាំ ដែលកំពុងចតទុកនៅក្នុងផ្ទះ ។ ភ្លាមនោះឈ្មោះ **បារាំង** បានឲ្យជនជាប់ចោទឈ្មោះ [redacted] ជីតា ចូលទៅលួចយកម៉ូតូរបស់ជនរងគ្រោះ ខណៈពេលជនជាប់ចោទកំពុងបណ្តើរម៉ូតូចេញ ក៏ស្រាប់តែជនរងគ្រោះបានឮសម្លេងម៉ូតូ និងបានចេញមកឃើញជនជាប់ចោទកំពុងតែបណ្តើរម៉ូតូ ក៏បានចាប់ខ្លួនជនជាប់ចោទបញ្ជូនឲ្យសមត្ថកិច្ចតែម្តង ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជីតា បានឆ្លើយថា នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១០៖៣០នាទីយប់ ខ្លួននិងឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ ០៩ឆ្នាំ បានជិះម៉ូតូកង់បីជាមួយបងប្រុសម្នាក់ឈ្មោះ **បារាំង** អាយុប្រហែល ៣០ឆ្នាំ រស់នៅម្តុំច្បារអំពៅ ពីភ្នំពេញទៅផ្ទះនៅភូមិព្រែកប៉ុល ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល លុះពេលធ្វើដំណើរតាមផ្លូវមកដល់ចំណុចភូមិស្តៅកន្លែង៤ ឃុំដីឥដ្ឋ ៘

ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក៏បានប្រទះឃើញម៉ូតូម៉ាកគប់ជ្រុង ដែលគេចតចោលនៅមុខផ្ទះ មិនមានចាក់សោរក រួចឈ្មោះ **បារាំង** ក៏បានខ្លួនចូលទៅលួចយកម៉ូតូនោះ ។ ខ្លួនក៏បានចូលទៅអូសម៉ូតូនោះ ក៏ស្រាប់តែម្ចាស់គេឃើញទាន់ ហើយចាប់ខ្លួនប្រគល់ឱ្យសមត្ថកិច្ចតែម្ដង ។ ខ្លួនធ្លាប់លួចគេបានចំនួន ០៥ដងហើយ គឺលួចមាន់ ទូរស័ព្ទ លុយ ម៉ូតូ និងប៉ុស្តិ៍ផ្សារដែក ហើយខ្លួនក៏ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៦ខែ ពីបទលួចដែរ ទើបតែចេញនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ។ ចំពោះឈ្មោះ បារាំង គឺខ្លួនធ្លាប់លួចជាមួយគាត់បានចំនួន ២-៣ដងដែរ ។

តុលាការយល់ឃើញថា ជនជាប់ចោទរូបនេះបានឆ្លើយសារភាព ដែលចម្លើយសារភាពនេះគឺស៊ីសង្វាក់នឹងចម្លើយជនរងគ្រោះឈ្មោះ [redacted] ចាន់ បានអះអាងថា នៅថ្ងៃកើតហេតុ ខ្លួនបានយកម៉ូតូមួយគ្រឿងម៉ាកគុបជ្រុងពណ៌ខៀវ ពាក់ស្លាកលេខ ធ១០៦៨ ភព ចតទុកចោលមុខផ្ទះរួចក៏សម្រាក លុះដល់ម៉ោង២២ ក៏លឺសម្លេងប្រោកៗ និងសំលេងឆ្កែព្រុស ខ្លួនក្រោកពីដេកចុះមកមើល ក៏មិនឃើញម៉ូតូ រួចខ្លួនក៏ស្រែកអោយគេជួយរក រួចក៏ឃើញក្មេងប្រុសម្នាក់អាយុប្រហែល១៦ឆ្នាំ កំពុងបណ្ដើរម៉ូតូខ្លួនតាមផ្លូវ ខ្លួនបានឃាត់នៅកន្លែង ហើយបានប្ដឹងសមត្ថកិច្ចប៉ុស្តិ៍នគរបាលដីឥដ្ឋ គប្បីតុលាការពិចារណា ។

៣-តាមរបាយការណ៍លេខ ០០៩ រ.ប.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ បានសន្និដ្ឋានថា ឈ្មោះ [redacted] ជីតា ភេទប្រុស អាយុ១៦ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួច (ម៉ូតូ) របស់ឈ្មោះ [redacted] ចន្ធូ ប្រាកដមែន ។

៤-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ជនជាប់ចោទគឺជាចោរអាជីព លួចពីតូចទៅធំ ជនជាប់ចោទទើបមានអាយុ ១៦ឆ្នាំ តែធ្លាប់បានលួចច្រើនដង ហើយធ្លាប់ជាប់ពន្ធនាគារទៀត ។ នៅដំណាក់កាលស៊ើបសួរ ជនជាប់ចោទបានព្យាយាមលាក់បាំងពីបក្សពួក ហើយទើបមកសារភាពនាពេលសវនាការនេះ គឺអាចវាយតម្លៃបានថា ជនជាប់ចោទមិនមានការរាងចាល គ្មានការភ្ញាក់រឭកទេ ហេតុនេះស្នើសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទក្នុងកម្រិតអតិបរមា មិនគប្បីផ្ដល់ស្ថានសម្រាលទេ ។ ឃើញថា ការសន្និដ្ឋានប្ដឹងសុំនេះមានលក្ខណៈត្រឹមត្រូវ គប្បីតុលាការពិចារណា ។

៥-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានសន្និដ្ឋានសុំឱ្យតុលាការផ្ដល់ស្ថានសម្រាលទោសដល់កូនក្ដីខ្លួន ដោយហេតុថាកូនក្ដីខ្លួនជាអនីតិជន ដែលងាយនឹងប្រព្រឹត្តបទល្មើសតាមការអូសទាញ ហើយមូលហេតុដែលកូនក្ដីខ្លួនលាក់បាំងបក្សពួក គឺដោយសារកូនក្ដីខ្លួនមិនយល់ ។

តុលាការឃើញថា ការសន្និដ្ឋាននេះមិនមានលក្ខណៈត្រឹមត្រូវទេ ម៉្យាងវិញទៀតបទល្មើសនេះគឺកំពុងតែកើនឡើងខ្លាំងនាពេលបច្ចុប្បន្ននេះ ហើយបានបង្កភាពចលាចលក្នុងសង្គមយ៉ាងធ្ងន់ធ្ងរ ដែលគប្បីត្រូវអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង និងមិនគួរមានការបន្ធូរបន្ថយទោសឡើយ ហេតុនេះតុលាការសម្រេចមិនលើកយកការសន្និដ្ឋាននេះមកធ្វើការពិចារណាឡើយ ។

៦-តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយជនរងគ្រោះ របាយការណ៍របស់សមត្ថកិច្ច និងភស្តុតាងក្នុងសំណុំរឿង ឃើញថាមានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងអង្គហេតុ ដែលអាចបញ្ជាក់បានថា កាលពីថ្ងៃទី ៤—



Scanned with CamScanner

២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] ជីតា ពិតជាបានធ្វើសកម្មភាពលួចយកម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] ចន្ធូ ម៉ាកគុបជ្រុង ដែលចតទុកចោលនៅមុខផ្ទះ ពេលដែលកំពុងអូសម៉ូតូចេញ ក៏ស្រាប់តែជនរងគ្រោះមកទាន់ ហើយចាប់ខ្លួនប្រគល់ឱ្យសមត្ថកិច្ចតែម្តង ប្រាកដមែន ។

៧-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ជីតា ពីបទ លួច (ម៉ូតូ) ប្រព្រឹត្តនៅស្តោកខ្លែង៤ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៨-តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ជីតា មានអាយុទើបតែ ១៦ឆ្នាំ ស្ថិតក្នុងវ័យអនីតិជន ហេតុនេះគប្បីតុលាការពិចារណានិងសម្រេចផ្តន្ទាទោសដោយផ្អែកតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

៩-វត្ថុចាប់យករួមមាន៖ ម៉ូតូម៉ាក គុបជ្រុង ពណ៌ខៀវ ផ្លាកលេខ ធ.១០៦៨.ភ.៣១ ចំនួន ០១គ្រឿង គប្បីតុលាការពិចារណាសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ដូចមានក្នុងកំណត់ហេតុប្រគល់និងទទួល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ។

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] ជីតា ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **១០ខែ** ពីបទ លួច (ម៉ូតូ) ប្រព្រឹត្តនៅស្តោកខ្លែង៤ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

២-វត្ថុចាប់យករួមមាន៖ ម៉ូតូម៉ាក គុបជ្រុង ពណ៌ខៀវ ផ្លាកលេខ ធ.១០៦៨.ភ.៣១ ចំនួន ០១គ្រឿង *ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ* ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជីតា និងប្រកាសជាសាធារណៈ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សាជំនុំជម្រះ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

កណ្តាល,ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]